អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- កំណើននៃការបញ្ជាទិញផលិតផលធ្វើដំណើរបានធ្វើឱ្យវិស័យមួយចំនួន ប្រឈមនឹងកង្វះកម្លាំងពលកម្ម
- ការនាំចេញដូងប្រេង(ផៅ)មានទឹកប្រាក់ជាង ៦៦លានដុល្លារ
- វិស័យកសិកម្ម ត្រូវការសេវាធានារ៉ាប់រងដើម្បីជានាការរីកចម្រើន
- ទីបំផុត ឥណ្ឌូនេស៊ីនឹងធ្វើការសម្រេចចិត្តអំពីការបើកឲ្យមានការនាំចេញធ្យូងថ្មឡើងវិញឆាប់ៗនេះ
- ផ្លែឈើស្រស់ថៃពឹងអាចនាំចេញតាម រថភ្លើងល្បឿនលឿនឡាវ-ចិន
- ទំនាក់ទំនងពាណិជ្ជកម្ម និងការវិនិយោគរបស់វៀតណាមជាមួយប្រទេសកម្ពុជា និងឡាវ
- សេដ្ឋកិច្ចថៃ នៅឆមាសទី១នេះនឹងមានកំណើនទាប ដោយសារតែជំងឺកូវីដ-១៩ ប្រភេទអូមីក្រុង
- វៀតណាម កំណត់គោលដៅ សេដ្ឋកិច្ចឆ្នាំ២០២២ នឹងសម្រេចក្នុងអត្រាកំណើន ៦,០ ទៅ ៦,៥%
- ការនាំចេញផលិតផលកសិកម្មវៀតណាមតាមផ្លូវសមុទ្រទៅចិនក៏ត្រូវបានផ្អាកដែរ
- ការរំពឹងទុករបស់អ្នកប្រើប្រាស់ចំពោះអតិផរណាមិនមានការប្រែប្រួលទេ ខណៈដែលធនាគារ Goldman Sachs បានព្យាករណ៍ថា ធនាគារកណ្ដាលអាមេរិក នឹងបង្កើនអត្រាការប្រាក់ ៤ដងនៅក្នុងឆ្នាំនេះ
- ប្រធានក្រុមហ៊ុនអាកាសចរ AirAsia បាននិយាយថា ការធ្វើដំណើរអន្តរជាតិនឹងមានសន្ទុះងើបឡើងវិញខ្លាំង ផុយពីផលប៉ះពាល់របស់ Omicron
- ស្រីលង្កា ស្នើចិនឱ្យជួយសម្រួលដល់លក្ខខណ្ឌសងបំណុល


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្ដាហ៍ទី៣ ខែមករា ឆ្នាំ២០២២ លេខ ៖ ១០២

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កំណើននៃការបញ្ជាទិញផលិតផលធ្វើដំណើរបានធ្វើឱ្យវិស័យមួយចំនួន ប្រឈមនឹងកង្វះកម្លាំងពលកម្ម



*ប្រភព៖ភ្នំពេញប៉ុស្តិ៍, ២០២១ រូបភាព៖ ហេង ជីវ័ន*

កំណើននៃការបញ្ជាទិញផលិតផលធ្វើដំណើរ និងស្បែកជើងពីទីផ្សារក្រៅប្រទេស និងការបើករោងចក្រថ្មីៗជាបន្តបន្ទាប់កំពុងធ្វើឱ្យវិស័យនេះប្រឈមនិងការខ្វះខាតកម្លាំងពលកម្ម។

យោងតាមប្រធានសមាគមស្បែកជើងកម្ពុជា លោក លី យុនថៃ បានបញ្ជាក់ថា៖ នៅក្នុងឆ្នាំ ២០២១ ការបញ្ជាទិញផលិតផលស្បែកជើង ពីទីផ្សារអន្តរជាតិបានកើនឡើងក្នុងរង្វង់ ៣០ %បើធៀបនឹងឆ្នាំ២០២០។ ការបញ្ជាទិញបានកើនឡើងច្រើន ជាពិសេសចាប់ពីត្រឹមពាក់កណ្តាលឆ្នាំ ២០២១ រហូតដល់ដើមឆ្នាំ ២០២២ ខណៈរោងចក្រមានការពង្រីកខ្សែសង្វាក់ផលិតច្រើន គួបផ្សំនឹងការបើករោងចក្រថ្មីៗជាច្រើន បណ្តាលឱ្យមានការខ្វះខាតកម្លាំងពលកម្មច្រើន ជាពិសេសនោះ ក្រុមកម្មករដែលមានជំនាញច្បាស់លាស់ ក្នុងការបំពេញការងារតាមរោងចក្រនៅតំបន់ជាយក្រុង។

ស្របពេលដែលប្រទេសកម្ពុជាគ្រប់គ្រងស្ថានភាពកូវីដ-១៩ បានល្អប្រសើរជាងគេក្នុងតំបន់អាស៊ាន និងការចាក់វ៉ាក់សាំងដល់ប្រជាជនស្ទើរ៩០% ហើយមានស្ថេរភាពនយោបាយផងនោះ បានធ្វើឱ្យអ្នកបញ្ជាទិញនៅក្រៅប្រទេសសម្រេចបង្វែរមកកម្ពុជាកាន់តែច្រើន ដែលនេះបង្ហាញថា ដំណើរការសេដ្ឋកិច្ចសកលលោកបានចាប់ផ្តើមវិលទៅរកភាពប្រក្រតីជាបណ្តើរឡើងវិញហើយ។

បញ្ហាកង្វះកម្លាំងពលកម្មជំនាញនេះ មិនត្រឹមតែកើតមានចំពោះវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងសម្ភារធ្វើដំណើរប៉ុណ្ណោះទេ ប៉ុន្តែវាកើតមានស្ទើរគ្រប់វិស័យពិសេសវិស័យកសិកម្ម។

ដើម្បីអាចប្រកួតប្រជែងជាមួយនឹងប្រទេសជិតខាង វិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងសម្ភារធ្វើដំណើរកម្ពុជាគឺកំពុងតែព្យាយាមកាត់បន្ថយថ្លៃដើមផលិត ដែលនេះជាចំណុចសំខាន់បណ្តាលឱ្យយើងជួបបញ្ហាកង្វះខាតកម្លាំងពលកម្ម។ ប្រសិនបើយើងហ៊ានឱ្យតម្លៃខ្ពស់ទៅលើកម្លាំងពលកម្មក្នុងស្រុកនោះ នឹងមិនមានការខ្វះខាតកម្លាំងពលកម្មទេ។

ប្រធានសមាគមស្បែកជើងបានស្នើសុំបង្កើតឱ្យមានកិច្ចព្រមព្រៀងលើអនុស្សរណៈនៃការយោគយល់គ្នាដើម្បីឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជួយស្វែងរកកម្លាំងពលកម្មសម្រាប់ផ្នែកផលិតស្បែកជើង និងផលិតផលធ្វើដំណើរផងដែរ។

គេរំពឹងថាឆ្នាំ២០២២នេះ និងមានកំណើននៃការវិនិយោគ និងការនាំចេញលើវិស័យកាត់ដេរ ស្បែកជើង

និងសម្ភារធ្វើដំណើរបន្ថែមទៀត ព្រោះកម្ពុជាមានច្បាប់វិនិយោគថ្មី ហើយការគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ ក៏ល្អផងដែរ ទោះបីបច្ចុប្បន្ននេះមានការផ្ទុះឡើងនូវមេរោគកូវីដបំលែងខ្លួនថ្មីអូមីក្រុងក៏ដោយ។

ទិន្នន័យក្រសួងពាណិជ្ជកម្មឱ្យដឹងថារយៈពេល ១០ ខែដំបូងឆ្នាំ២០២១ កម្ពុជានាំចេញសម្ភារធ្វើដំណើរ និងស្បែកជើង មានតម្លៃសរុបចំនួន ២ ២៩៣ លានដុល្លារ។ ក្នុងនោះការនាំចេញស្បែកជើង មានតម្លៃ ១ ១១៤ លានដុល្លារ កើនឡើង ២១%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ និងការនាំចេញសម្ភារៈធ្វើដំណើរ មានទឹកប្រាក់ ១ ១៧៩ លានដុល្លារ កើនឡើង ចំនួន៥២%។

*ដោយ សេន ចន្ទ*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍,ចេញផ្សាយថ្ងៃទី១០ខែមករា ឆ្នាំ២០២១*

## ការនាំចេញដូងប្រេង(ផ្លៅ)មានទឹកប្រាក់ជាង ៦៦ លានដុល្លារ



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១, រូបភាព៖ហេង ជីវ៉ន់*

យោងតាមអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម លោក ងិន ឆាយ បានលើកឡើងថា៖ បើទោះបីពិភពលោកជួបនឹងវិបត្តិកូវីដ-១៩ ក៏តម្រូវការដូងប្រេងនៅលើទីផ្សារអន្តរជាតិនៅតែមានបរិមាណច្រើនដដែល។

កម្ពុជាបាននាំចេញដូងប្រេង(ផ្លៅ) ទៅកាន់ទីផ្សារអន្តរជាតិក្នុងបរិមាណសរុបជិត ៦២ ០០០ តោន ទទួលបានចំណូលជាង ៦៦លានដុល្លារ ក្នុងឆ្នាំ២០២១ កើនឡើង ១៧៦% បើធៀបនឹងឆ្នាំ២០២០។ ការនាំចេញនេះដូងប្រេង(ផ្លៅ)ក្នុងតម្លៃ ១ ០៦៥ដុល្លារក្នុងមួយតោន។

បច្ចុប្បន្នក្រៅពីការវិនិយោគរបស់ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុបនៅខេត្តព្រះសីហនុ ក៏មានក្រុមហ៊ុនវៀតណាមកំពុងវិនិយោគនៅក្នុងខេត្តមណ្ឌលគិរីផងដែរ។

សម្រាប់ការនាំចេញដូងប្រេង(ផ្លៅ) របស់ក្រុមហ៊ុន ម៉ុង ឫទ្ធី ក្នុងឆ្នាំ២០២១ សម្រេចបានប្រមាណ ៤៧ ០០០ តោន កើនឡើង ៣% បើធៀបនឹងឆ្នាំ ២០២០។ ការកើនឡើងនេះដោយសារក្នុងឆ្នាំ ២០២១ អាកាសធាតុមានភាពអំណោយផល (ភ្លៀងច្រើន) ដែលធ្វើឱ្យដូងមានផ្លែច្រើន។

ទីផ្សារដែលទទួលទិញដូងប្រេងពីកម្ពុជា មានដូចជាប្រទេសឥណ្ឌា សហគមន៍អឺរ៉ុប និងម៉ាឡេស៊ី ជាដើម។ ការដាំដុះដូងប្រេងនៅកម្ពុជានៅមានតិចតួចនៅឡើយបើធៀបជាមួយប្រទេសក្នុងតំបន់អាស៊ានដូចជា ថៃ និងម៉ាឡេស៊ី។បច្ចុប្បន្នផ្ទៃដីដាំដូងប្រេងរបស់ក្រុមហ៊ុនមានត្រឹមតែជាង ២០ ០០០ ហិកតា ហើយក្រុមហ៊ុនកំពុងមានផែនការពង្រីកការដាំដុះដូងប្រេងឱ្យកើនដល់ ៣០ ០០០ហិកតា ដើម្បីបង្កើតរោងចក្រកែច្នៃផលិតផលជាប្រេងឆានៅក្នុងស្រុក ដោយពុំចាំបាច់នាំចេញទៅក្រៅប្រទេស។

ម៉ុង ឫទ្ធីគ្រុប គឺជាក្រុមហ៊ុនដែលវិនិយោគលើការដាំដូងប្រេងធំជាងគេនៅកម្ពុជា និងជាប់ចំណាត់ថ្នាក់ទី ៤ នៅអាស៊ីអាគ្នេយ៍។ ក្រុមហ៊ុនបានចាប់ផ្ដើមវិនិយោគលើការដាំដូងប្រេង ក្នុងឆ្នាំ ១៩៩៦។

សព្វថ្ងៃក្រុមហ៊ុនមានរោងចក្រកែច្នៃកិនយកប្រេងដូងចំនួន ២ ដែលមានសមត្ថភាពផលិតបាន ៧៥ តោនក្នុង ១ ម៉ោង។ ក្រុមហ៊ុនរំពឹងថា នឹងអាចនាំចេញដូង

ប្រេង (ឆៅ) បានយ៉ាងតិច ៥០ ០០០ តោន ក្នុងឆ្នាំ ២០២២ នេះ។ *ដោយ មុំ ចិន្តា*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ២០២២*

## ការអភិវឌ្ឍប៉ែកខាងជើងភ្នំពេញមានការរីកចម្រើនខ្លាំង នៅប៉ុន្មានឆ្នាំចុងក្រោយនេះ



*ប្រភព ៖ ខេមបូណូមីស*

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ែកខាងជើងរាជធានីភ្នំពេញ មានគម្រោងបុរីលំនៅដ្ឋានធំៗ និងអគារពាណិជ្ជកម្មជាច្រើនបានសម្រុកបន្តសាងសង់ជាបន្តបន្ទាប់។ កត្តាដែលជំរុញឱ្យវិនិយោគិនអចលនទ្រព្យផ្តោតទៅតំបន់នោះកាន់តែខ្លាំង ដោយសារតំបន់នេះមានខ្យល់អាកាស និងទឹកគ្រប់គ្រាន់ ដែលអំណោយផលដល់ការរស់នៅ និងប្រកបអាជីវកម្មរបស់ប្រជាពលរដ្ឋ។ តំបន់នោះ ក៏ជាបណ្តុំដោយអាគារពាណិជ្ជកម្ម ផ្សារទំនើប សាលារៀន មន្ទីរពេទ្យ និងស្ថាប័នរដ្ឋមួយចំនួនទៀតដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងសាធារណការ និងដឹកជញ្ជូន, ពហុកីឡដ្ឋានជាតិមរតកតេជោ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗមួយចំនួនទៀត ត្រូវបានលេចត្រដែតឡើង ដែលជាសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍ។ ពិសេសទៅទៀតតំបន់នោះមានដីធំៗទំនេរច្រើន ដែលអំណោយផលដល់ការអភិវឌ្ឍអគារពាណិជ្ជកម្ម ខុនដូ ផ្សារទំនើប និងអគារលំនៅឋានធំៗ។

ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុមើលឃើញថា តាមរយៈការអភិវឌ្ឍរបស់ក្រុមហ៊ុនធំៗទាំងនេះ រួមជាមួយវត្តមានក្រសួង ស្ថាប័នរដ្ឋមួយចំនួន វានឹងធ្វើឱ្យការអភិវឌ្ឍន៍នៅតំបន់នោះមានការរីកចម្រើនខ្លាំងនាពេលអនាគត។

វិស័យសំណង់ និងអចលនទ្រព្យក្នុងឆ្នាំ២០២១ មានការរីកចម្រើនប្រហាក់ប្រហែលនឹងឆ្នាំ២០២០ ទោះបីឆ្នាំ២០២១ កម្ពុជាបានរងផលប៉ះពាល់ខ្លាំងពីវិបត្តិកូវីដ-១៩ ក៏ដោយ។ តាមការរំពឹងពីអ្នកជំនាញ វិស័យអចលនទ្រព្យកម្ពុជានៅឆ្នាំ២០២២ នឹងមានកំណើនចន្លោះពី១០%ទៅ១៥%។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០៦ខែមករា ឆ្នាំ២០២២។*

## វិស័យកសិកម្ម ត្រូវការសេវាធានារ៉ាប់រងដើម្បីធានាការរីកចម្រើន



*(រូបភាព៖ CRF)កសិករក្នុងខេត្តបាត់ដំបងកំពុងច្រូតស្រូវ*

វិស័យកសិកម្មនៅកម្ពុជា ជាវិស័យមួយដែលងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។ ក្រុមហ៊ុនធានារ៉ាប់រងហ្វតេ ក្រោមការសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងរាជរដ្ឋាភិបាលកម្ពុជា គ្រោងដាក់ឱ្យប្រើប្រាស់ផលិតផលធានារ៉ាប់រងលើវិស័យកសិកម្មនៅអំឡុងខែកុម្ភៈ ឆ្នាំ២០២២ ខាងមុខនេះ។ គោលបំណងនៃការដាក់ឱ្យប្រើប្រាស់សេវាធានារ៉ាប់រងលើវិស័យកសិកម្មនេះ គឺដើម្បីកាត់បន្ថយហានិភ័យដែលជាបញ្ហាប្រឈម និងរក្សាសន្តិសុខស្បៀងជូនប្រជាពលរដ្ឋ ជួយអភិវឌ្ឍន៍វិស័យកសិកម្ម

កម្ពុជា និងជួយរក្សាស្ថិរភាពប្រាក់ចំណូលជូនប្រជាពលរដ្ឋ។

ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនធានារ៉ាប់រង Forte បានអះអាងថា អ្នកប្រកបរបរក្នុងវិស័យកសិកម្ម អាចនឹងថយចុះ ប្រសិនបើខ្វះការយកចិត្តទុកដាក់ និងសេវាធានារ៉ាប់រង។ នៅពេលអ្នកប្រកបរបរក្នុងវិស័យនេះថយចុះ វាអាចនឹងជះឥទ្ធិពលមិនល្អដល់វិស័យកសិកម្មទាំងមូល ដែលអាចធ្វើឱ្យប៉ះពាល់ដល់ផែនការនាំចេញផលិតផលកសិកម្ម និងការរក្សាសន្តិសុខស្បៀងជូនប្រជាពលរដ្ឋជាដើម។ លោកបានគូសបញ្ជាក់ថា លោក រួមជាមួយអង្គការជាដៃគូ កំពុងសិក្សាផ្តល់សេវាធានារ៉ាប់រងលើវិស័យចិញ្ចឹមត្រីដែលកំពុងមានការពេញនិយមខ្លាំងនាពេលបច្ចុប្បន្ន។ អ្នកចិញ្ចឹមត្រី នឹងជួបហានិភ័យខ្ពស់បើបន្តចិញ្ចឹមដោយគ្មានការធានារ៉ាប់រងដូចបច្ចុប្បន្ន។ ផលិតផលធានារ៉ាប់រងលើវិស័យកសិកម្ម គ្រោងអនុវត្តជំហានដំបូងនៅភូមិជាង១ពាន់ក្នុងខេត្តចំនួន៣រួមមានខេត្តព្រៃវែង កំពង់ធំ និងបាត់ដំបង ដោយរំពឹងទទួលបានការរួម១២ម៉ឺននាក់៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី០៧ ខែមករា ឆ្នាំ២០២២។*

## ក្រុមហ៊ុនAeon គ្រោងបង្កើតទីតាំងស្តុក និងដឹកជញ្ជូនទំនិញលក្ខណៈអន្តរជាតិនៅខេត្តព្រះសីហនុ




*ដោយ ខេមបូណ្ឌមីស(ការដើរទិញទំនិញនៅផ្សារទំនើបAeonនៅប្រទេសជប៉ុន)*

ក្រុមហ៊ុនដ៏ធំរបស់ជប៉ុន Aeon មានគោលដៅផ្តល់សេវាកម្មដឹកជញ្ជូន និងចែកចាយជាអន្តរជាតិនៅក្នុងប្រទេសកម្ពុជា។ សេវាកម្មថ្មីនេះត្រូវបានទាក់ទាញដោយការកើនឡើងនៃពាណិជ្ជកម្មអេឡិចត្រូនិក និងពាណិជ្ជកម្មឆ្លងព្រំដែនរបស់តំបន់អាស៊ីអាគ្នេយ៍។ ផ្សារទំនើប អ៊ីអនម៉ល (Aeon Mall) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Aeon គ្រោងនឹងសាងសង់មជ្ឈមណ្ឌលដឹកជញ្ជូន ទំហំប្រហែល៣ម៉ឺនម៉ែត្រការ៉េ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្បែរកំពង់ផែ ភាគខាងត្បូងនៃខេត្តព្រះសីហនុ ដែលគ្រោងចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ២០២៣។ គម្រោងមជ្ឈមណ្ឌលដឹកជញ្ជូននេះ គឺបង្កើតជាទីតាំងស្តុកទំនិញនាំចូល សេវាបង់ប្រាក់គយព្រមទាំងជួយដល់ការលក់រាយតាមអ៊ិនធឺណិតឆ្លងព្រំដែនផងដែរ ធ្វើឱ្យកម្ពុជាក្លាយជាទីតាំងស្តុកទំនិញដ៏សំខាន់ និងជំបូងគេរបស់ Aeon នៅក្នុងតំបន់។ អ្នកនាំទំនិញចូលពីក្រៅប្រទេស អាចស្តុកទំនិញនៅទីនេះដោយមិនចាំបាច់បង់ថ្លៃកាតព្វកិច្ច មុនពេលឆ្លងកាត់និតិវិធីរបស់អាជ្ញាធរគយ។ ចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬE-Commerce អន្តរជាតិនៅក្នុងតំបន់ក៏កំពុងមានការពង្រីកកាន់តែខ្លាំងឡើងដែរ។ តួយ៉ាងក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកយក្សរបស់ចិនគឺ Alibaba Group ក៏បានផ្តោតការយកចិត្តទុកដាក់មកលើទីផ្សារកម្ពុជាដែរ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយក្រុមហ៊ុនធំៗរបស់ជប៉ុនក៏កំពុងមានផ្តល់សេវាកម្មជាច្រើននៅកម្ពុជាដែរ។

គម្រោងអភិវឌ្ឍន៍នេះបានទទួលការជួយគាំទ្រពីរដ្ឋាភិបាលជប៉ុន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនហៅកាត់ថា JICA។ ជាក់ស្តែង កាលពាក់កណ្តាលខែធ្នូ ឆ្នា២០២១ កន្លងទៅនេះរដ្ឋាភិបាលជប៉ុន បានប្រកាសផ្តល់ហិរញ្ញប្បទាន ឥតសំណងចំនួនប្រមាណ

១៤លានដុល្លារអាមេរិកដល់កម្ពុជា សម្រាប់ការបំពាក់គ្រឿងចក្រលើកដាក់ទំនិញចល័តនៅកំពង់ផែក្រុងព្រះសីហនុ។

បន្ទាប់ពីកម្ពុជា Aeon គ្រោងនឹងពង្រីកសេវាកម្មដូចគ្នាទៅកាន់ប្រទេស២ផ្សេងទៀតក្នុងតំបន់អាស៊ាន ដូចជាឥណ្ឌូនេស៊ី និងម៉ាឡេស៊ី៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌីសចេញផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ២០២២។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១ ៖ ការចំណាយលើអត្ថប្រយោជន៍សង្គមប្រចាំខែតុលា ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា នៅក្នុងខែតុលាឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិបានចំណាយលើអត្ថប្រយោជន៍សង្គម ក្នុងទំហំទឹកប្រាក់សរុបចំនួន ៤០៥,៦៤ប៊ីលានរៀល ដែលមានការធ្លាក់ចុះប្រមាណជា ៨,៤%បើធៀបនឹងខែកញ្ញា នៃឆ្នាំ២០២១។

ជាក់ស្តែង ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គម មានទឹកប្រាក់ចំនួន ៩៩,៦៥ប៊ីលានរៀល នៅក្នុងខែតុលាឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ៤,៨% បើធៀបនឹងខែកញ្ញា ឆ្នាំ២០២១។

ទន្ទឹមនឹងនោះដែរ ការចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន២៩៥,៤៥ប៊ីលានរៀល នៅក្នុងខែតុលាឆ្នាំ២០២១ មានការធ្លាក់ចុះប្រមាណជា ១០,៥៧% បើធៀបនឹងខែកញ្ញា ឆ្នាំ២០២១។

ស្របពេលនោះដែរ ការចំណាយលើអំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ មានទំហំទឹកប្រាក់៥,៣១ប៊ីលានរៀល នៅក្នុងខែតុលាឆ្នាំ២០២១ មានការធ្លាក់ចុះប្រមាណជា៣៣,៦៣% បើធៀបនឹងខែកញ្ញា។

ដោយឡែក ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត មានទឹកប្រាក់ចំនួន ៥,២៣ប៊ីលានរៀល នៅក្នុងខែតុលាឆ្នាំ២០២១៕

ដោយ មិត្ត ចន្ទី

| ការចំណាយឆ្នាំ២០២១(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា |
|---|---|---|---|---|---|---|---|---|---|---|
| **អត្ថប្រយោជន៍សង្គម** | **103.40** | **114.72** | **240.59** | **115.28** | **376.94** | **365.53** | **479.33** | **364.04** | **443.06** | **405.64** |
| **កំណើន/ថយ(%)** | | 10.9% | 109.7% | -52.1% | 227.0% | -3.0% | 31.1% | -24.1% | 21.7% | -8.4% |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 90.63 | 101.04 | 158.63 | 39.06 | 92.81 | 99.99 | 99.76 | 94.59 | 104.7 | 99.65 |
| **កំណើន/ថយ(%)** | | 11.5% | 57.0% | -75.4% | 137.6% | 7.7% | -0.2% | -5.2% | 10.7% | -4.8% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 9.54 | 8.85 | 75.32 | 65.65 | 266.78 | 255.92 | 370.71 | 257.70 | 330.36 | 295.45 |
| **កំណើន/ថយ(%)** | | -7.2% | 751.1% | -12.8% | 306.4% | -4.1% | 44.9% | -30.5% | 28.2% | -10.57% |
| អំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ | 3.23 | 4.83 | 6.64 | 10.57 | 11.73 | 9.62 | 8.86 | 8.94 | 8.00 | 5.31 |
| **កំណើន/ថយ(%)** | | 49.5% | 37.5% | 59.2% | 11.0% | -18.0% | -7.9% | 0.9% | -10.5% | -33.63% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | - | - | - | - | 5.62 | - | | 2.81 | - | 5.23 |

ប្រភព៖តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ខែតុលាឆ្នាំ២០២១

### តារាងទី២ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសថៃលើមុខទំនិញ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ធនាគារជាតិប្រទេសថៃ បានបង្ហាញថា នៅក្នុងខែវិច្ឆកាឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលមានទំហំទឹកប្រាក់សរុប ៦៤២,០៣លានដុល្លារ បានធ្លាក់ចុះប្រមាណជា ៧,២% បើធៀបនឹងខែតុលានៃឆ្នាំដដែល។

ជាក់ស្តែង ការនាំចូលទំនិញរបស់ប្រទេសថៃមកកម្ពុជា មានទំហំទឹកប្រាក់សរុប ៥៧៥លានដុល្លារ នៅក្នុងខែវិច្ឆកាឆ្នាំ២០២១ បានធ្លាក់ចុះប្រមាណជា ៩,១% បើធៀបនឹងខែតុលា ឆ្នាំ២០២១។

ក៏ប៉ុន្តែ ការនាំចេញទំនិញរបស់កម្ពុជាទៅប្រទេសថៃ មានទំហំទឹកប្រាក់សរុប ៦៧,០៣លានដុល្លារ នៅក្នុងខែវិច្ឆិកាឆ្នាំ២០២១ មានកំណើនប្រមាណជា១៣,៦% បើធៀបនឹងខែតុលា ឆ្នាំ២០២១។

ដោយ មិត្ត ចន្ទី

*ឯកតា៖ គិតជាលានដុល្លារអាមេរិក*

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **653.39** | **644.76** | **799.19** | **596.61** | **671.83** | **616.20** | **630.47** | **625.27** | **732.42** | **691.86** | **642.03** |
| កំណើន% | | -1.3% | 24.0% | -25.3% | 12.6% | -8.3% | 2.3% | -0.8% | 17.1% | -5.5% | -7.2% |
| កម្ពុជានាំចេញទៅថៃ | 113.22 | 112.05 | 104.27 | 72.63 | 57.65 | 55.93 | 52.97 | 54.51 | 63.79 | 59.03 | 67.03 |
| កំណើន% | | -1.0% | -6.9% | -30.3% | -20.6% | -3.0% | -5.3% | 2.9% | 17.0% | -7.5% | 13.6% |
| ថៃនាំចូលមកកម្ពុជា | 540.17 | 532.71 | 694.92 | 523.98 | 614.18 | 560.27 | 577.50 | 570.76 | 668.63 | 632.83 | 575.00 |
| កំណើន% | | -1.4% | 30.4% | -24.6% | 17.2% | -8.8% | 3.1% | -1.2% | 17.1% | -5.4% | -9.1% |

ប្រភព៖ *ធនាគារជាតិប្រទេសថៃ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ទីបំផុត ឥណ្ឌូនេស៊ីនឹងធ្វើការសម្រេចចិត្តអំពីការបើកឲ្យមានការនាំចេញធ្យូងថ្មឡើងវិញឆាប់ៗនេះ



*ដោយ ៖ ខេមបូណូមីស*

ឥណ្ឌូនេស៊ី បានចាប់ផ្តើមផ្អាកការនាំចេញធ្យូងថ្មចាប់តាំងពីថ្ងៃទី១ខែមករាមក បន្ទាប់ពីមានរបាយការណ៍បង្ហាញថា កម្រិតស្តុកប្រេងឥន្ធនៈមានទាប ដែលអាចបង្កការខ្វះខាតថាមពល និងធ្វើឱ្យអគ្គិសនីនឹងត្រូវកាត់ផ្តាច់ញឹកញាប់។ បច្ចុប្បន្ន ក្រុមហ៊ុនសហព័ន្ធថាមពលឥណ្ឌូនេស៊ី ដែលជាក្រុមហ៊ុនរដ្ឋរបស់ឥណ្ឌូនេស៊ី បានប៉ាន់ប្រមាណថា នៅក្រោយពេលផ្អាកការនាំចេញរយៈពេល១០ថ្ងៃមកនេះ ក្រុមហ៊ុនបានស្តុកធ្យូងថ្មបានប្រមាណ ១៤លានតោន ប៉ុន្តែ គេចង់បង្កើនឱ្យបានដល់ ២០លានតោន នៅក្នុងរយៈពេល២០ថ្ងៃសម្រាប់បម្រើដល់រោងចក្រថាមពលនៅក្នុងប្រទេស។

ក្រោយពី ឥណ្ឌូនេស៊ីផ្អាកការនាំចេញធ្យូងថ្ម ប្រទេសជប៉ុន ហ្វីលីពីន និងកូរ៉េខាងត្បូងដែលជាអ្នកបញ្ជាទិញបានអំពាវនាវឱ្យឥណ្ឌូនេស៊ីដកបម្រាមនាំចេញធ្យូងថ្មនេះផងដែរ ដោយសារតែបារម្ភពីផលប៉ះពាល់ដល់តម្រូវការប្រើប្រាស់ថាមពល។ ប្រទេសចិន មិនបានចេញមុខអំពាវនាវឱ្យដកចោលបម្រាមនេះនោះទេ បើទោះបីចិនកំពុងប្រឈមនឹងការខ្វះខាតថាមពល ក្រោយមានជម្លោះជាមួយអូស្ត្រាលីក៏ដោយ។

រដ្ឋមន្ត្រីក្រសួងថាមពលឥណ្ឌូនេស៊ី បានអះអាងថា រដ្ឋាភិបាល នឹងអាចសម្រេចឱ្យមានការនាំចេញធ្យូងថ្មឡើងវិញ ខណៈដែលសម្ពាធកំពុងមានការកើនឡើងលើក្រុមហ៊ុននាំចេញធ្យូងថ្ម។ ឥណ្ឌូនេស៊ីបានស្តុកទុកធ្យូងថ្មបានច្រើន ហើយនៅប៉ុន្មានថ្ងៃខាងមុខនេះ ស្តុកធ្យូងថ្មនឹងកើនក្នុងចំនួនច្រើនទៀត ដូច្នេះ ឥណ្ឌូនេស៊ីអាចនឹងមានសន្តិសុខធ្យូងថ្មគ្រប់គ្រាន់ ដែលអាចបើកឱ្យមានការនាំចេញឡើងវិញឆាប់ៗនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ២០២២។*

### ផ្លែឈើស្រស់ថៃរំពឹងអាចនាំចេញតាម រថភ្លើងល្បឿនលឿនឡាវ-ចិន




*ដោយ ខេមបូណូមីស (រថភ្លើងដឹកជញ្ជូនទំនិញនៅប្រទេសចិន)*

ប្រទេសថៃ បានមើលឃើញឱកាសល្អនៃការធ្វើពាណិជ្ជកម្មឆ្លងដែន ហើយបានគ្រោងនឹងចរចាជាមួយរដ្ឋាភិបាលឡាវ និងចិន សម្រាប់កិច្ចសហប្រតិបត្តិការដឹកជញ្ជូន

ទំនិញតាមរថភ្លើងល្បឿនលឿនឡាវ-ចិន ដើម្បីជួយជំរុញដល់ការនាំចេញផ្លែឈើស្រស់របស់ប្រទេសថៃឱ្យមានវិសាលភាពធំធេង។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មថៃបានឱ្យដឹងថា ប្រសិនបើការចរចារសម្រេចបានជោគជ័យមែន នោះនឹងជួយលើកកម្ពស់ពាណិជ្ជកម្មឆ្លងព្រំដែនរួមរវាងថៃ និងឡាវព្រមទាំងចិនផងដែរ។ បច្ចុប្បន្ននេះ ភាគីថៃកំពុងធ្វើការលើយុទ្ធសាស្ត្រពាណិជ្ជកម្មព្រំដែន ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃគម្រោងរថភ្លើងល្បឿនលឿនឡាវ-ចិន ក៏ដូចជាការស្វែងរកមធ្យោបាយជំរុញការនាំចេញ និងពាណិជ្ជកម្មឆ្លងព្រំដែនរបស់ខ្លួនផងដែរ។ ខណៈបច្ចុប្បន្ននេះប្រទេសចិនអនុញ្ញាតឱ្យដឹកជញ្ជូនទំនិញមួយចំនួន ដូចជា រ៉ែ កៅស៊ូ និងដំឡូងមីតែប៉ុណ្ណោះ តាមរយៈផ្លូវរថភ្លើងល្បឿនលឿននេះ។ ដូច្នេះហើយបានជាប្រទេសថៃចង់ចរចាជាមួយរដ្ឋាភិបាលចិន ដើម្បីអនុញ្ញាតឱ្យការដឹកជញ្ជូនផ្លែឈើស្រស់របស់ថៃនៅក្នុងរដូវប្រមូលផលខាងមុខនេះបន្ថែមទៀត។

កាលពីឆ្នាំមុន ទំហំពាណិជ្ជកម្មព្រំដែន ថៃ-ឡាវ បានកើនឡើងដល់ជិត ៦ ពាន់លានដុល្លារ មានកំណើនជាង ១២% ធៀបទៅនឹងឆ្នាំមុន។ ក្នុងនោះ ការនាំចេញពីប្រទេសថៃមានចំនួនជាង ៣ពាន់ ៣រយលានដុល្លារ កើនឡើងជាង ២០% ពីឆ្នាំ ២០២០ ដែលបណ្ដាលឱ្យថៃមានអតិរេកពាណិជ្ជកម្មមានតម្លៃជាង ៩រយលានដុល្លារ ពីពាណិជ្ជកម្មតាមព្រំដែនថៃ-ឡាវនេះ។

ក្រៅតែពីការចរចារនាំចេញទំនិញតាមរថភ្លើងល្បឿនលឿននេះ រដ្ឋាភិបាលថៃក៏បានបង្កើតក្រុមការងារមួយដើម្បីសម្របសម្រួលឱ្យកាន់តែល្អជាមួយអាជ្ញាធរដឹកជញ្ជូនក្នុងប្រទេសឡាវលើគម្រោងសាងសង់ផ្លូវរថភ្លើងតភ្ជាប់ប្រទេសជិតខាងទាំងពីរផងដែរ៕ *ដោយ ម៉ែន ខេមរៈ ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១២ ខែមករា ឆ្នាំ២០២២។*

## ទំនាក់ទំនងពាណិជ្ជកម្ម និងការវិនិយោគរបស់វៀតណាមជាមួយ ប្រទេសកម្ពុជា និងឡាវ



*ដោយ ខេមបូណ្ឌមីស(រូបតំណាងពាណិជ្ជកម្មវៀតណាម និងឡាវ)*

នៅពេញមួយឆ្នាំ២០២១នេះ ទំហំពាណិជ្ជកម្មរវាងវៀតណាម និងឡាវ មានប្រមាណ ១ ៣០០លានដុល្លារអាមេរិក កើនប្រមាណ៣០% បើធៀបនឹងឆ្នាំ២០២០។ ចំពោះវៀតណាម និងកម្ពុជាគិតត្រឹម១១ខែ ឆ្នាំ២០២១សម្រេចបានដល់ទៅជាង៨ ០០០លានដុល្លារ កើនឡើងជាង៨៤%។ ការប្រៀបធៀបទំហំពាណិជ្ជកម្មរវាងវៀតណាម និងឡាវមានតូចជាង រវាងវៀតណាម ជាមួយកម្ពុជា។ ប៉ុន្តែចំពោះការវិនិយោគវិញ បច្ចុប្បន្ននេះវៀតណាមមានគម្រោងវិនិយោគដែលមានសុពលភាពចំនួន ២០៩ នៅឡាវក្នុងដើមទុនចុះបញ្ជីសរុបប្រមាណជាង ៥ ០០០លានដុល្លារអាមេរិក។ ហើយកាលពីឆ្នាំ២០២១ បានវិនិយោគលើគម្រោងថ្មីចំនួន៥បន្ថែមទៀត។ គម្រោងទាំងនោះកំពុងមានសកម្មភាពល្អ បង្កើតការងារដ៏មានស្ថិរភាពសម្រាប់ពលកររាប់ម៉ឺននាក់ និងរួមចំណែកយ៉ាងសំខាន់ក្នុងដំណើរការជំរុញវិស័យសេដ្ឋកិច្ចឡាវផងដែរ។ ដោយឡែក ការវិនិយោគរបស់វៀតណាមនៅកម្ពុជា គិតមកដល់បច្ចុប្បន្ននេះមានលើគម្រោងចំនួន១៨៨គម្រោង និងមានទុនចុះបញ្ជីសរុបជាង២៨០០លានដុល្លារអាមេរិក។ ហើយនៅត្រឹម១១ខែ ឆ្នាំ២០២១ វៀតណាមបានវិនិយោគគម្រោងថ្មីចំនួន ៤គម្រោងនៅកម្ពុជា ដែលមានដើម

ទុនចុះបញ្ជីជិត៩០លានដុល្លារអាមេរិកប៉ុណ្ណោះ។ ដូច្នេះ បើប្រៀបធៀបទំហំវិនិយោគឃើញថា វៀតណាម បានវិនិយោគនៅឡាវ ច្រើនជាងនៅកម្ពុជាដល់ទៅប្រមាណជាង២ ០០០លានដុល្លារ។ វៀតណាម និង ឡាវ ក៏កំពុងដោះស្រាយការលំបាកដែលកំពុងជួបប្រទះ ជាពិសេសទាក់ទងនឹងដើមទុន ការបង់ពន្ធ ការនាំចូល-នាំចេញ និងការជួលដី និងក៏មានការព្រមព្រៀងបង្កើតច្រករបៀងស្របច្បាប់ ដើម្បីដោះដូរពាណិជ្ជកម្មផងដែរ។ ក្នុងឆ្នាំ ២០២២នេះ ភាគីឡាវ និងវៀតណាម បានឯកភាពជំរុញកំណើននៃទំហំពាណិជ្ជកម្មដោយខិតខំសម្រេចបាននូវការកើនឡើងប្រកបដោយស្ថិរភាព ១០% ឬខ្ពស់ជាងនេះ ធៀបនឹងឆ្នាំ២០២១៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១២ ខែមករា ឆ្នាំ២០២២។*

## សេដ្ឋកិច្ចថៃ នៅឆមាសទី១នេះ ត្រូវបានរំពឹងថា នឹងមានកំណើនទាប ដោយសារតែការរីករាលនៃជំងឺកូវីដ-១៩ ប្រភេទអូមីក្រុង



*ប្រភព៖ The Business Times, រូបភាព៖ AFP*

ធនាគារកណ្តាលប្រទេសថៃ បានលើកឡើងកាលពីពេលថ្មីៗនេះថា ការរីករាលដាលនៃវីរុសអូមីក្រុង បានបង្កឱ្យមានភាពមិនប្រាកដប្រជា ដែលជាលទ្ធផលធ្វើឱ្យកំណើនសេដ្ឋកិច្ចមានកម្រិតទាបជាងសេណារីយ៉ូគោល សម្រាប់រយៈពេល ៦ខែដំបូង ក្នុងឆ្នាំ២០២២។ ដោយឡែក ស្ថានភាពការផ្ទុះឡើងនៃវីរុសប្រភេទថ្មី អូមីក្រុងនេះ ត្រូវបានរំពឹងថា នឹងអាចគ្រប់គ្រងបាន ក្នុងត្រីមាសទី១នេះ។ គួរបញ្ជាក់ថា ធនាគារកណ្តាលថៃ បានព្យាករថា សេដ្ឋកិច្ចឆ្នាំ២០២២ នឹងសម្រេចក្នុងអត្រាកំណើន ៣,៤%។

ទន្ទឹមនេះ យោងតាមទិន្នន័យរបស់ធនាគារកណ្តាលថៃ បង្ហាញថា ស្ថិរភាពហិរញ្ញវត្ថុនៅតែមានភាពផុយស្រួយសម្រាប់គ្រួសារ និងអាជីវកម្ម ខណៈដែល កម្ចីខូច បានកើនឡើងបន្តិច បើយោងតាមការលើកឡើងរបស់លោក Sakkapop Panyanukul នាយកជាន់ខ្ពស់នៃធនាគារកណ្តាលថៃ។

ចំណែកឯ អតិផរណា ឃើញមានការកើនឡើង នៅក្នុងឆមាសទី១នេះ ប៉ុន្តែស្ថិតក្នុងអត្រាគោលដៅ។ ក្នុងនោះដែរ អត្រាប្តូរប្រាក់បាតធៀបនឹងដុល្លារ បានកើនដល់ ៣៣,១៤បាតក្នុង ១ដុល្លារ ដែលស្ថិតក្នុងកម្រិតខ្ពស់ គិតចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០២១មក។ ក្នុងករណីដែល លុយបាតមានការប្រែប្រួលខ្លាំង នោះធនាគារកណ្តាលនឹងធ្វើអន្តរាគមន៍៕ *ដោយ ជា សិរីរតន៍*

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២*

## វៀតណាម កំណត់គោលដៅ សេដ្ឋកិច្ចឆ្នាំ២០២២ នឹងសម្រេចក្នុងអត្រាកំណើន ៦,០ ទៅ ៦,៥%



*ប្រភព៖ Phnome Penh Post, រូបភាព៖ Vietnam News Agency*

រដ្ឋាភិបាលវៀតណាម បានកំណត់គោលដៅកំណើនសេដ្ឋកិច្ចឆ្នាំនេះ ក្នុងចន្លោះ ៦,០% ទៅ ៦,៥%។ គួរបញ្ជាក់ថា គោលដៅនេះនឹងអាចសម្រេចបាន បើវិធានការការពារឆ្លងនៅបន្តមានប្រសិទ្ធភាពខ្ពស់។ ថ្វីបើនៅ

មានការបន្តការរិតត្បិត ដែលប៉ះពាល់យ៉ាងខ្លាំងទៅដល់ជីវភាពរស់នៅប្រជាជន និងអាជីវកម្ម ក៏ប៉ុន្តែសេដ្ឋកិច្ចបានបង្ហាញនូវចំណុចល្អប្រសើរជាច្រើន។

ទន្ទឹមនេះដែរ ដោយសារតែការរីករាលដាលជាថ្មីនៃវីរុសប្រភេទថ្មី អូមីក្រុង ក្នុងប្រទេស និងពិភពលោក បានបង្កឱ្យមានភាពលំបាកក្នុងការសម្រេចគោលដៅនេះ។

ដោយឡែក ជាផ្នែកមួយនៃផែនការងើបឡើងវិញនៃសេដ្ឋកិច្ច រដ្ឋាភិបាលវៀតណាម បានបន្តគាំដល់វិស័យធុរកិច្ច និងកែលម្អបរិយាកាសវិនិយោគ ក៏ដូចជា ពង្រឹងវិធានការគ្រប់គ្រងជំងឺរាតត្បាត។

ជាក់ស្តែង កិច្ចការចម្បងក្នុងឆ្នាំ២០២២នេះ គឺត្រូវសម្របខ្លួនដោយសុវត្ថិភាព និងគ្រប់គ្រងជំងឺរាតត្បាតជាមួយនឹងភាពបត់បែន និងប្រកបដោយប្រសិទ្ធភាព, កែសម្រួលអភិបាលកិច្ចឱ្យកាន់តែមានភាពល្អប្រសើរឡើង, គាំទ្រអាជីវកម្ម និងកែលម្អបរិយាកាសធុរកិច្ច។

គួរកត់សម្គាល់ផងដែរ ក្នុងឆ្នាំ២០២១ វៀតណាម បានទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ក្នុងទំហំសរុប ៧,២៣ ប៊ីលានដុល្លារ កើនប្រមាណ ៣៨,៤៨% ពីឆ្នាំ២០២០។ ទន្ទឹមនេះដែរ ការងារប្រមាណជា ១៤០ ០០០ត្រូវបានបង្កើត និងអត្រាគ្មានការងារធ្វើ រក្សាបាននៅក្រោម ៤%៕

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ Phnom Penh Post ចេញផ្សាយ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២*

## ការនាំចេញផលិតផលកសិកម្មវៀតណាមតាមផ្លូវសមុទ្រទៅចិនត្រូវបានផ្អាក




*ដោយ ខេមបូណ្ណមីស(ការនាំចេញផលិតផលកសិកម្មវៀតណាម-ចិន)*

បញ្ហាដឹកជញ្ជូនឆ្លងកាត់ព្រំដែនរវាងវៀតណាម និងចិន នៅតែបន្តជាប់គាំង បើទោះបីជាប្តូរពីការដឹកជញ្ជូនតាមផ្លូវគោកមកតាមផ្លូវសមុទ្រក៏ដោយ។ រដ្ឋាភិបាលចិនកំពុងមានការរឹតបន្តឹងខ្លាំងលើការនាំចូលទំនិញចាប់តាំងពីដើមឆ្នាំ២០២២មក ក្រោមវិធានការទប់ស្កាត់កូវីដ១៩ដ៏តឹងរ៉ឹង។ កំពង់ផែនៅប្រទេសចិនក៏កំពុងមានការកកស្ទះដែរ ដោយសារតែមានភាពយឺតយ៉ាវលើនិតិវិធីត្រួតពិនិត្យ និងបង់ពន្ធគយ ក្រោមគោលការណ៍ការពារកូវីដ១៩របស់ប្រទេសចិន។

សមាគមបន្លែ និងផ្លែឈើវៀតណាមបានអះអាងថា សកម្មភាពនាំចេញតាមផ្លូវសមុទ្រទៅកាន់ប្រទេសចិននៅ១សប្តាហ៍ចុងក្រោយនេះ គឺពិតជាមានភាពយឺតយ៉ាវខ្លាំងណាស់។ មានការបញ្ជាទិញជាច្រើន តែនៅកកស្ទះនៅត្រឹមសមុទ្រ ដែលវាប្រឈមនឹងការខាតបង់ ប្រសិនបើកំពង់ផែនៅតែកកស្ទះយ៉ាងដូច្នេះ។

នៅសប្តាហ៍នេះ កំពង់ផែសមុទ្ររបស់ចិន នឹងមានបុគ្គលិកឈប់សម្រាកនៅមុនថ្ងៃបុណ្យចូលឆ្នាំចិន ដូច្នេះ វាអាចនឹងធ្វើឱ្យនីតិវិធីត្រួតពិនិត្យ និងបង់ពន្ធគយនឹងកាន់តែលំបាកថែមទៀត។

ដោយសារតែវិធានការរឹតបន្តឹងកូវីដ១៩តឹងរ៉ឹងពីសំណាក់រដ្ឋាភិបាលចិន ការដឹកជញ្ជូនទំនិញតាមច្រកព្រំដែនគោករវាងវៀតណាម និងចិនមានការកកស្ទះយ៉ាងខ្លាំង ដោយមានឡានកុងតឺន័រដឹកជញ្ជូនទំនិញរាប់ពាន់គ្រឿងកកស្ទះនៅតាមព្រំដែនវៀតណាម ហើយក្នុងនោះ មាន៦០% គឺជាកុងតឺន័រដឹកជញ្ជូនផ្លែឈើស្រស់របស់វៀតណាមទៅចិន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ណមីស ចេញផ្សាយថ្ងៃទី១១ខែមករា ឆ្នាំ២០២២។*

## តើវៀតណាមនឹងទាញយកផលចំណេញរយៈពេលវែងអ្វីខ្លះពីកិច្ចព្រមព្រៀងពាណិជ្ជកម្ម RCEP?



*ដោយ ខេមបូណ្ឌាមីស*

អ្នកជំនាញសេដ្ឋកិច្ច និងអ្នកជំនួញធំៗនៅវៀតណាម អះអាងថា កិច្ចព្រមព្រៀងពាណិជ្ជកម្មដ៏ធំបំផុតរបស់ពិភពលោក គឺកិច្ចព្រមព្រៀងពាណិជ្ជកម្មភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ ដែលហៅកាត់ថា RCEP នឹងជំរុញពាណិជ្ជកម្មវៀតណាមក្នុងរយៈពេលវែង នឹងក្លាយជាផ្នែកមួយនៃខ្សែសង្វាក់ផ្គត់ផ្គង់កាន់តែធំទៅកាន់ពិភពលោក។ ក្នុងនោះដែរ ប្រទេសចិន និងជប៉ុន កំពុងក្លាយជាគោលដៅទីផ្សារដ៏សំខាន់សម្រាប់វៀតណាមក្នុងការនាំចេញតាមរយៈកិច្ចព្រមព្រៀង RCEP នេះ។

អ្នកជំនួញនាំចេញគ្រឿងសមុទ្រធំៗរបស់វៀតណាម បានឱ្យដឹងថា RCEP ដែលបានចូលជាធរមានកាលពីថ្ងៃទី ១ ខែមករាកន្លងទៅនេះ នឹងជួយក្រុមហ៊ុននាំចេញគ្រឿងសមុទ្រ ទាញយកអត្ថប្រយោជន៍កាន់តែច្រើន និងលើកទឹកចិត្តពួកគេឱ្យអភិវឌ្ឍន៍ឧស្សាហកម្មប្រកបដោយនិរន្តរភាពជាមួយនឹងទំហំផលិតកម្មកាន់តែធំស្របទៅតាមច្បាប់អន្តរជាតិ។ ក្រុមហ៊ុនអាហារសមុទ្រត្រូវបានកំណត់ថា នឹងស្ថិតក្នុងចំណោមអ្នកទទួលបានផលប្រយោជន៍ដ៏សំខាន់ ខណៈដែលប្រទេសជាសមាជិកកិច្ចព្រមព្រៀង RCEP ភាគច្រើន លើកលែងតែកូរ៉េខាងត្បូងមួយ បានយល់ព្រមកាត់បន្ថយពន្ធលើអាហារសមុទ្រដល់សូន្យភាគរយភ្លាមៗនៅពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មចូលជាធរមាន។ ទន្ទឹមនេះ ក្រុមហ៊ុននាំចេញផ្លែឈើមានក្តីរំពឹងថា តាមរយៈកិច្ចព្រមព្រៀង RCEP នឹងអាចជួយពួកគេនាំចេញផ្លែឈើកាន់តែច្រើនទៅក្រៅប្រទេស។ ជាក់ស្តែង ជាឧទាហរណ៍ប្រទេសចិនគ្រោងនឹងនាំចូលជាផ្លូវការនូវផ្លែឈើបន្ថែមទៀតពីប្រទេសវៀតណាម រួមមាន ធុរេន ផ្លែល្ហុង ក្រូចថ្លុង ផ្លែបឺរ និងផ្លែប៉ោម។ យ៉ាងណាមិញ ក៏មានឧស្សាហកម្មជាច្រើនផ្សេងទៀត ដូចជាសម្លៀកបំពាក់ ស្បែកជើង ឈើ សេវាកម្ម និងការផលិតផ្សេងទៀត ក៏នឹងទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មនេះផងដែរ។

វៀតណាមនៅតែជាប្រទេសមួយក្នុងចំណោមប្រទេសដែលពឹងផ្អែកលើពាណិជ្ជកម្មច្រើនជាងគេ នៅក្នុងពិភពលោក។ បច្ចុប្បន្ន ការនាំចេញរបស់វៀតណាមទៅកាន់បណ្តាប្រទេសជាសមាជិកកិច្ចព្រមព្រៀង RCEP មានដល់ទៅ ៥២%នៃការនាំចេញសរុប។ ដោយឡែកទំហំពាណិជ្ជកម្មវៀតណាមជាមួយប្រទេសជាដៃគូសម្រេចបានដល់ ៦៦៨ពាន់លានដុល្លារកើនជាង ២២% ក្នុងឆ្នាំ ២០២១។ វៀតណាមក៏រំពឹងដែរថា កិច្ចព្រមព្រៀង RCEP នឹងអាចផ្តល់នូវសន្ទុះសម្រាប់ការងើបឡើងនៃសេដ្ឋកិច្ចក្រោយការរាតត្បាតកូវីដ១៩ផងដែរ។

សូមរំឭកថា កិច្ចព្រមព្រៀងពាណិជ្ជកម្មភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ដ៏ធំ RCEPនេះ ត្រូវបានចុះហត្ថលេខាដោយប្រទេសចំនួន ១៥ ដែលគ្របដណ្តប់សរុបប្រហែលមួយភាគបីនៃចំនួនប្រជាជនពិភពលោក ដែលអនុញ្ញាតឱ្យអាជីវកម្មមានការកាត់បន្ថយពន្ធនាំចូលដល់ទៅ ៩២% ខណៈដែលមានទី

ផ្សារហេតុដល់ជាង២ពាន់២រយលាននាក់ និងជាប្លុកពាណិជ្ជកម្មសេរីដ៏ធំបំផុតនៅក្នុងពិភពលោក៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១០ ខែមករា ឆ្នាំ២០២២។*

## សេដ្ឋកិច្ចសកល

## ការរំពឹងទុករបស់អ្នកប្រើប្រាស់ចំពោះអតិផរណាមិនមានការប្រែប្រួលទេ ខណៈដែលធនាគារ Goldman Sachs បានព្យាករណ៍ឃើញថា ធនាគារកណ្ដាលរបស់សហរដ្ឋអាមេរិក នឹងបង្កើនអត្រាការប្រាក់ ៤ដងនៅក្នុងឆ្នាំនេះ



*ប្រធានធនាគារកណ្ដាលលោក Jerome Powell ថ្លែងនៅក្នុងកិច្ចប្រជុំការគណៈកម្មាធិការសេវាហិរញ្ញវត្ថុរបស់សភា ស្ដីពីការត្រួតពិនិត្យរបស់នាយកដ្ឋានរតនាគារ និងការឆ្លើយតបចំពោះជំងឺរាតត្បាតរបស់ធនាគារកណ្ដាលនៅអគារ Rayburn ថ្ងៃពុធ ទី០១ ខែធ្នូ ឆ្នាំ២០២១។*

*រូបថត៖ CNBC Tom Wiliams/CQ-Roll Call, Inc, /Getty Images*

យោងតាមការស្ទង់មតិបានបង្ហាញថា ការរំពឹងទុករបស់អ្នកប្រើប្រាស់នៅក្នុងរយៈពេលខ្លីចំពោះអតិផរណានៅសហរដ្ឋអាមេរិកកាលពីខែធ្នូមិនមានការប្រែប្រួលទេ ទោះបីជាវាមានការកើនឡើងអស់រយៈពេលជាងមួយឆ្នាំកន្លងមកក្ដី។ ពួកគេបានបន្ទាបការរំពឹងទុកចំពោះការកើនឡើងនៃថ្លៃទំនិញចាំបាច់នៅក្នុងឆ្នាំ២០២២។ ពួកគេបានរំពឹងថា នៅក្នុងឆ្នាំនេះថ្លៃហ្គាសនឹងកើនឡើងត្រឹម ៥,៧% ទាបជាងខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានអត្រាកំណើន ៩,២% និងការកើនឡើងនៃថ្លៃម្ហូបអាហារនឹងមានអត្រាត្រឹម ៧,៨% ទាបជាងខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានការកើនឡើងដល់ទៅ ៩,២%។

ទន្ទឹមនឹងនេះអ្នកប្រើប្រាស់នៅសហរដ្ឋអាមេរិកហាក់មានភាពសុទិដ្ឋិនិយមចំពោះទីផ្សារការងាររបស់ពួកគេ ដោយបានរំពឹងថា អត្រានៃការបាត់បាត់ការងារនៅសហរដ្ឋអាមេរិកនឹងធ្លាក់ចុះក្នុងអំលុងពេល ១២ ខែខាងមុខ។ ព្រោះអត្រាបាត់បង់ការងារនៅសហរដ្ឋអាមេរិកកាលពីខែធ្នូ ឆ្នាំ២០២១ បានធ្លាក់ចុះពី ១២,៩% នៅក្នុងខែវិច្ឆិកាមកនៅត្រឹម ១១,៦% នៅក្នុងខែធ្នូ។ ចំណែកឯមធ្យមភាគចំពោះឱកាសស្វែងរកការងារសម្រាប់អ្នកដែលបាត់បង់ការងារវិញបានកើនឡើងពី ៥៥,៩% នៅក្នុងខែវិច្ឆិកា ដល់ ៥៧,៥% នៅក្នុងខែធ្នូ ពោលគឺបានកើនឡើងដល់កម្រិតមួយខ្ពស់បំផុត បើធៀបទៅនឹងដំណាក់កាលដំបូងនៃជំងឺរាតត្បាតកូវីដ១៩ ដែលបានចាប់ផ្ដើមកាលពីខែកុម្ភៈ ឆ្នាំ២០២០ ដែលមានអត្រា ៥៨,៧%។

ដើម្បីឆ្លើយតបចំពោះការកើនឡើងនៃអតិផរណា និងដើម្បីឆ្លើយតបចំពោះការរឹតបន្តឹងទីផ្សារការងារ មន្ត្រីធនាគារកណ្ដាលរបស់សហរដ្ឋអាមេរិកបាននិយាយថា ពួកគេនឹងតម្លើងអត្រាការប្រាក់ឱ្យខ្ពស់ជាងការរំពឹងទុក និងប្រហែលជាត្រូវចាប់ផ្ដើមកាត់បន្ថយមូលប័ត្របំណុលក្នុងពេលឆាប់ៗខាងមុខ។

លោក Hatziu ប្រធានក្រុមសេដ្ឋវិទូ the Wall Street បានលើកឡើងផងដែរថា ការធ្លាក់ចុះទីផ្សារការងារ ឬការរឹតបន្តឹងទីផ្សារការងារនៅសហរដ្ឋអាមេរិកបានធ្វើឱ្យការកើនឡើងនៃអត្រាអតិផរណាកាន់តែមានភាពរសើប និងកាន់តែប្រឈមនឹងហានិភ័យ។ ហេតុនេះហើយអត្រាការប្រាក់នៅសហរដ្ឋអាមេរិកនឹងបន្តកើនឡើងជាបន្តបន្ទាប់នៅចុងត្រីមាស

នីមួយៗក្នុងឆ្នាំ២០២២ គឺនៅក្នុងខែមីនា ខែមិថុនា ខែកញ្ញា និងនៅក្នុងខែធ្នូ ឆ្នាំនេះ៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ Reuters និង CNBC ចេញផ្សាយ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២*

## ប្រធានក្រុមហ៊ុនអាកាសចរ AirAsia បាននិយាយថា ការធ្វើដំណើរអន្តរជាតិនឹងមានសន្ទុះងើបឡើងវិញខ្លាំង ផ្ទុយពីផលប៉ះពាល់របស់ Omicron



*ប្រភព៖ CNBC*

ប្រធានក្រុមហ៊ុនអាកាសចរ AirAsia បាននិយាយថា ការធ្វើដំណើរអន្តរជាតិទំនងជានឹងងើបឡើងវិញក្នុងពេលឆាប់ៗខាងមុខនេះ ផ្ទុយពីការរំពឹងទុកដែលថា ផលប៉ះពាល់របស់ Omicron វ៉ាំជ្យង់នាំឱ្យការងើបឡើងវិញរបស់ការធ្វើដំណើរជាអន្តរជាតិមានកំណើនឡើងវិញយឺត។ លោកបាននិយាយថា កាលពីឆ្នាំមុនយើងគ្មានជើងហោះហើរទាល់តែសោះ ប៉ុន្តែឥឡូវនេះយើងមានជើងហោះហើរក្នុងស្រុកនៅម៉ាឡេស៊ី ថៃ និងឥណ្ឌូនេស៊ី ដោយសារតែតម្រូវការមានកើនឡើងយ៉ាងខ្លាំង។ លោកមានសុទិដ្ឋិនិយមថា ការធ្វើដំណើរអន្តរជាតិនឹងវិលត្រលប់ទៅរកសភាពដើមដូចស្ថានភាពមុនពេលមានវិបត្តិកូវីដ១៩ នៅក្នុងអំលុងពេល ៦ខែបន្ទាប់ខាងមុខទៀត ក្រោយពីប្រទេសមួយចំនួនបានប្រកាសបើកបើកព្រំដែនឡើងវិញ។ ហេតុនេះលោកសង្ឃឹមថា ការបើកព្រំដែននឹងមានដំណើរការជាថ្មីឡើងវិញម្តងទៀតនៅក្នុងខែមីនា ឆ្នាំនេះ។ ខណៈដែលសំណួរនេះត្រូវបានចោទសួរយ៉ាងរសើបចំពោះការបើកព្រំដែនរបស់ចិន នៅពេលដែលរដ្ឋាភិបាលចិនកំពុងតែអនុវត្តគោលនយោបាយ «Zero-Covid policy»។ លោកបានបន្ថែមថា អាជីវកម្មជើងហោះហើររបស់ក្រុមហ៊ុនលោកមានដំណើរការល្អមិនគួរឱ្យជឿ និងហួសពីការរំពឹងទុក ចាប់ពីក្រុមហ៊ុននេះបានបើកឱ្យដំណើរការឡើងវិញកាលពីខែសីហា ឆ្នាំ២០២១៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ CNBC ចេញផ្សាយ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២*

## ស្រីលង្កា ស្នើចិនឱ្យជួយសម្រួលដល់លក្ខខណ្ឌសងបំណុល



*ដោយ ខេមបូឌាមីស*

ស្រីលង្កាជាប្រទេស ដែលមានសេដ្ឋកិច្ចពឹងផ្អែកខ្លាំងលើវិស័យទេសចរណ៍ ប៉ុន្តែដោយសារវងគ្រោះធ្ងន់ធ្ងរពីវិបត្តិជំងឺរាតត្បាតកូវីដ១៩ បានធ្វើឱ្យប្រទេសនេះ ខាតបង់ប្រាក់ជាច្រើនពីប្រភពចំណូលវិស័យទេសចរណ៍ដ៏ចម្បងមួយនេះ។ ស្រីលង្កាបាននិងកំពុងជួបវិបត្តិខ្វះថវិកាខ្លាំង រហូតដល់ត្រូវបង្ខំចិត្តឱ្យរដ្ឋាភិបាល ដកលុយពីកញ្ចប់បម្រុងរូបិយប័ណ្ណបរទេសទៅចាយវាយ ដោះស្រាយបញ្ហាមួយគ្រាសិនផងដែរ។ ស្រីលង្កាបានទទួលអត្ថប្រយោជន៍ច្រើន ពីកម្ចីរាប់ពាន់លានដុល្លារពីទីក្រុងប៉េកាំង។ ប្រទេសចិនបានផ្តល់កម្ចីសម្រាប់គម្រោងផ្លូវល្បឿនលឿន, កំពង់ផែ, ព្រលានយន្តហោះ និងរោងចក្រថាមពលដើរដោយធ្យូងថ្មជាដើម ប៉ុន្តែមិនបានផ្តល់ផលប្រយោជន៍ដូចអ្វីដែលបានរំពឹងទុកនោះទេ។ បច្ចុប្បន្នប្រទេសមួយនេះកំពុងធ្លាក់ចុះទៅក្នុងវិបត្តិហិរញ្ញវត្ថុកាន់តែអាក្រក់ទៅៗ។ គិតត្រឹមដំណាច់ខែវិច្ឆិ

កា ឆ្នាំ ២០២១ កញ្ចប់ថវិកាបម្រុងរូបិយប័ណ្ណបរទេសរបស់ស្រីលង្កានៅសល់តែ ១ ៥០០លានដុល្លារប៉ុណ្ណោះ។ បន្ថែមពីលើការបំពេញតម្រូវការចាយវាយក្នុងស្រុក រដ្ឋាភិបាលស្រីលង្កាក៏ត្រូវការសងប្រាក់ទៅម្ចាស់បំណុលដែរ។ ប្រទេសស្រីលង្កាត្រូវសងបំណុលសរុបប្រហែល៤ពាន់៥រយលានដុល្លារនៅក្នុងឆ្នាំ២០២២នេះ ដោយនឹងចាប់ផ្តើមសងនៅត្រឹមថ្ងៃទី១៨ ខែមករានេះ។

ប្រធានាធិបតីប្រទេសស្រីលង្កាបានស្នើសុំទៅកាន់ប្រទេសចិន ដែលជាម្ចាស់បំណុលរបស់ខ្លួន ឱ្យពន្យាពេលសងបំណុល ដើម្បីរួមចំណែកជួយសម្រាលបន្ទុករដ្ឋាភិបាលស្រីលង្កា ស្របពេលដែលប្រទេសនេះកំពុងដើរលើផ្លូវទៅរកវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ។ ការស្នើសុំនេះធ្វើឡើងក្នុងអំឡុងពេល ដែលប្រមុខការទូតចិនធ្វើដំណើរទស្សនកិច្ចមកកាន់ប្រទេសមួយនេះកាលពីថ្ងៃអាទិត្យទី០៩ មករា។ មកដល់ពេលនេះ មិនមានការឆ្លើយតបភ្លាមៗណាមួយពីភាគីចិនទៅកាន់សំណើខាងលើនេះទេ រីឯស្ថានទូតចិនប្រចាំនៅស្រីលង្កា ក៏មិនបាននិយាយអ្វីជុំវិញបញ្ហាការស្នើសុំពន្យាសងបំណុលនេះដែរ។

ចិនជាអ្នកផ្តល់ប្រាក់កម្ចីទ្វេភាគីទៅឱ្យស្រីលង្កាធំជាងគេលំដាប់ទី៤ បន្ទាប់ពី មូលនិធិហិរញ្ញវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងប្រទេសជប៉ុន។ គិតត្រឹមខែមេសាឆ្នាំ២០២១ រដ្ឋស្រីលង្កាជំពាក់បំណុលចិនដល់ទៅ៣ពាន់៥រយលានដុល្លារអាមេរិក៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ២០២២។*

## ឥណ្ឌាបើកឱ្យអាមេរិកនាំចូលសាច់ជ្រូកឡើងវិញ ក្រោយផ្អាកនាំចូលអស់មួយរយៈធំ




*ដោយ ខេមបូណ្ឌមីស(INDIA US PORK IMPORT)*

ប្រទេសឥណ្ឌាបានអនុញ្ញាតឱ្យនាំចូលសាច់ជ្រូក និងផលិតផលសាច់ជ្រូករបស់អាមេរិកឡើងវិញ ក្រោយពីបានផ្អាកអស់មួយរយៈធំ។ អាមេរិកបានសម្លឹងឃើញឥណ្ឌាជាទីផ្សារដ៏មានសក្តានុពលសម្រាប់ទំនិញរបស់ខ្លួន ជាពិសេសក្រោយទំនាក់ទំនងរវាងឥណ្ឌា និងចិនកាន់តែតានតឹងទៅៗ ដែលនេះជាឱកាសថ្មីមួយ ដើម្បីទទួលបានទីផ្សារសម្រាប់សាច់ជ្រូកអាមេរិកទៅកាន់ប្រទេសឥណ្ឌា ហើយវាជាសញ្ញានៃសកម្មភាពវិជ្ជមាននៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម រវាងសហរដ្ឋអាមេរិក និងឥណ្ឌាផងដែរ។ ប្រទេសទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីអនុញ្ញាតឱ្យមានការនាំចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិកនូវផ្លែស្វាយ និងផ្លែទទឹមរបស់ឥណ្ឌា ហើយអាមេរិកក៏បាននាំចូលទៅកាន់ប្រទេសឥណ្ឌាវិញនូវផលិតផលកសិកម្មមួយចំនួនផងដែរ។

ឥណ្ឌា គឺជាប្រទេសដែលមានប្រជាជនច្រើនជាងគេទីពីររបស់ពិភពលោក បន្ទាប់ពីប្រទេសចិន ដែលមានតម្រូវប្រើប្រាស់ផលិតផលម្ហូបអាហារ ផ្លែឈើ គ្រាប់ធញ្ញជាតិ ផលិតផលទឹកដោះគោ និងផលិតផលបសុសត្វផ្សេងទៀតកំពុងកើនឡើងក្នុងចំណោមអ្នកប្រើប្រាស់ឥណ្ឌា សហរដ្ឋអាមេរិកឯណោះវិញក៏ជាអ្នក

ផលិតធំជាងគេទី ៣ របស់ពិភពលោកផងដែរ ហើយជាប្រទេសនាំចេញសាច់ជ្រូកធំបំផុតទីពីរក្នុងឆ្នាំ ២០២០ ដោយការលក់សាច់ជ្រូក និងផលិតផលធ្វើពីសាច់ជ្រូករបស់អាមេរិកនៅទូទាំងសកលលោក។

ការបើកភ្លើងខៀវពីប្រទេសឥណ្ឌាសម្រាប់ការនាំចូលសាច់ជ្រូកពីអាមេរិកនេះ វាគឺជារឿងវិជ្ជមានសម្រាប់ទីផ្សារសាច់ជ្រូកអាមេរិក ខណៈដែលថ្មីៗនេះ កោះតៃវ៉ាន់ក៏បានបោះឆ្នោតសម្រេចមិនបិទខ្ទប់ការនាំចូលសាច់ជ្រូកពីអាមេរិកទៅតៃវ៉ាន់ដែរ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១២ ខែមករា ឆ្នាំ២០២២។*

**អាមេរិកត្រូវបង្កើនទំនាក់ទំនងសេដ្ឋកិច្ចកាន់តែខ្លាំងក្លាថែមទៀត ជាមួយតំបន់ឥណ្ឌូប៉ាស៊ីហ្វិកនៅឆ្នាំខាងមុខនេះ**




*ដោយ ខេមបូណ្ឌមីស( កិច្ចប្រជុំរបស់អាមេរិក ជាមួយប្រទេសជាសមាជិក Quad)*

មន្ត្រីសម្របសម្រួលតំបន់ឥណ្ឌូប៉ាស៊ីហ្វិករបស់សេតវិមានអាមេរិក បានលើកឡើងថា សហរដ្ឋអាមេរិកត្រូវការបង្កើនទំនាក់ទំនងសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីឱ្យកាន់តែខ្លាំងក្លាថែមទៀត នៅឆ្នាំខាងមុខនេះ។ ប្រធានាធិបតីអាមេរិក បានសម្រេចយ៉ាងច្បាស់លាស់នូវអ្វីដែលអាមេរិកត្រូវការ ដើម្បីដើរតួនាទីសំខាន់នៅក្នុងទំនាក់ទំនងសេដ្ឋកិច្ចពាណិជ្ជកម្ម ក៏ដូចជាការអនុវត្តដោះដូរពាណិជ្ជកម្មនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ស្របពេលដែលឥទ្ធិពលរបស់ចិនក៏កំពុងរីកសាយភាយកាន់តែខ្លាំងផងដែរនៅក្នុងតំបន់នេះ។ នៅមានអ្វីផ្សេងទៀត ដែលអាមេរិកត្រូវតែបង្កើនសកម្មភាពរបស់ខ្លួននៅក្នុងទំនាក់ទំនងសេដ្ឋកិច្ចជាមួយនឹងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ តួនាទីរបស់អាមេរិក ត្រូវតែបន្តធ្វើអ្វី ក្រៅពីសកម្មភាពពាណិជ្ជកម្មតាមបែបប្រពៃណី ហើយនោះគឺរួមមានបញ្ចូលនូវទំនាក់ទំនងឌីជីថល និងការកំណត់នូវស្តង់ដារបច្ចេកវិទ្យាជាដើម។ អាមេរិកមិនត្រឹមតែមានទំនងទំនងស៊ីជម្រៅខាងផ្នែកការទូត យោធា គ្រប់ជ្រុងជ្រោយ និងជាយុទ្ធសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែ អាមេរិកត្រូវតែមានការបើកចំហ មានការចូលរួម និងសុទិដ្ឋិនិយមចំពោះសមាហរណកម្មពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកផងដែរ។ នៅឆ្នាំ២០២២នេះ នឹងបន្តធ្វើកិច្ចការទាំងអស់នេះ សម្រាប់ទំនាក់ទំនងគ្រប់ជ្រុងជ្រោយនៅទូទាំងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ បើនិយាយពីប្រទេសនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកខ្លះ គឺពួកគេមានទំនាក់ទំនងពាណិជ្ជកម្មដ៏ធំសម្បើមជាមួយនឹងចិន ប៉ុន្តែ អាមេរិកវិញ គឺមិនទាន់មានទំនាក់ទំនងពាណិជ្ជកម្មច្រើនជាមួយប្រទេសទាំងនោះនៅឡើយទេ។ តួយ៉ាង នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ដ៏ធំចំនួន២ គឺ RCEP និង CP TPP ក៏មិនមានវត្តមានអាមេរិកចូលរួមដែរ ប៉ុន្តែ ក្នុងនោះ ចិនបានចូលរួមរួចហើយនៅក្នុងកិច្ចព្រមព្រៀង RCEP ដែលត្រូវបានចូលជាធរមាននៅដើមខែមករានេះ។ បន្ថែមពីនេះ ចិនក៏កំពុងស្នើសុំចូលរួមក្នុងកិច្ចព្រមព្រៀង CP TPP ដែរ។ កិច្ចព្រមព្រៀងទាំងនេះ គឺមានប្រទេសជាសមាជិកភាគច្រើន នៅក្នុងតំបន់តំបន់អាស៊ី។

ទោះបីអាមេរិក មិនបានចូលរួមក្នុងកិច្ចព្រមព្រៀងទាំងនេះក៏ដោយ ប៉ុន្តែ ទីក្រុងវ៉ាស៊ិនតោន នឹងជំរុញឱ្យមានការចរចាបង្កើតក្របខ័ណ្ឌសេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិកថ្មីមួយនាពេលខាងមុខនេះ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១០ ខែមករា ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១៧ ខែមករា ឆ្នាំ២០២២

- កំណើនសេដ្ឋកិច្ចចិន បានកើនឡើង 4.9%ក្នុងត្រីមាសទី 3 នៃឆ្នាំ 2021
- កំណើនអត្រានីកម្មភាព នៅទីក្រុងដែលបានស្ទង់មតិរបស់ប្រទេសចិនបានកើនឡើងដល់ 5.0%នៅក្នុងខែវិច្ឆិកា 2021

ថ្ងៃអង្គារ ទី១៨ ខែមករា ឆ្នាំ២០២២

- អត្រានីកម្មភាព របស់ចក្រភពអង់គ្លេសបានធ្លាក់ចុះមកនៅត្រឹម 4.2% ក្នុងរយៈពេលបីខែដល់ខែតុលា ឆ្នាំ 2021
- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអ៊ីតាលីបានរួមតូចមកត្រឹម 3 888 ពាន់លានអឺរ៉ូក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃពុធ ទី១៩ ខែមករា ឆ្នាំ២០២២

- អត្រាអតិផរណាតម្លៃទំនិញប្រើប្រាស់របស់អាល្លឺម៉ង់ត្រូវបានគេរំពឹងថានឹងកើនឡើងដល់ 5.3%នៅក្នុងខែធ្នូ ឆ្នាំ 2021
- សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់នៅចក្រភពអង់គ្លេសបានកើនឡើង 0.70%ក្នុងខែវិច្ឆិកា ឆ្នាំ 2021 ធៀបនឹងខែមុន

ថ្ងៃព្រហស្បតិ៍ ទី២០ ខែមករា ឆ្នាំ២០២២

- ការនាំចេញពីប្រទេសជប៉ុនបានកើនឡើង ក្នុងខែវិច្ឆិកា ឆ្នាំ 2021
- ឱនភាពពាណិជ្ជកម្មរបស់ប្រទេសអេស្ប៉ាញបានកើនឡើងយ៉ាងខ្លាំងដល់ 3.4 ពាន់លានអឺរ៉ូក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃសុក្រ ទី២១ ខែមករា ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអាហ្សង់ទីនបានកើនឡើងដល់ 397 លានដុល្លារក្នុងខែវិច្ឆិកា ឆ្នាំ 2021
- ការលក់ដុំក្នុងប្រទេសកាណាដាទំនងជាកើនឡើង 2.7% ក្នុងខែវិច្ឆិកា ឆ្នាំ 2021៕